# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

លេខ:...................

# ឯកសារដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ

## ស្តីពី

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# ការផ្គត់ផ្គង់ខ្សាច់ទន្លេ

**ឈ្មោះក្រុមហ៊ុន/សហគ្រាស:**...........................................................................................

**អាសយដ្ឋានទាក់ទង:**...................................................................................................

.............................................................................................................................

**ទូរស័ព្ទលេខ:**..........................................**ទូរសារលេខ:**...........................................

**គេហទំព័រ:**...............................................................................................................

កាលបរិច្ឆេទទទួលសំណើដេញថ្លៃ រៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃ នៅម៉ោង ១៤:០០នាទី ថ្ងៃទី០៧ខែកក្កដាឆ្នាំ២០២៤

# មាតិកា


| ល.រ | បរិយាយ | ទំព័រ |
|---|---|---|
| ១ | សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមដេញថ្លៃ | 3 |
| ២ | សេចក្តីណែនាំចំពោះអ្នកដេញថ្លៃ | 5 |
| ៣ | លក្ខខណ្ឌនៃកិច្ចសន្យា | 12 |
| ៤ | ពាក្យសុំដេញថ្លៃ ( ឧបសម្ព័ន្ធទី១ ) | 18 |
| ៥ | តារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស ( ឧបសម្ព័ន្ធទី២) | 20 |
| ៦ | សេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មរបស់អ្នកដេញថ្លៃ | 23 |
| ៧ | ប៉ាន់គំរូ ឬកាតាឡុក | 25 |
| ៨ | ទម្រង់លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ ( ឧបសម្ព័ន្ធទី៣ ) | 26 |
| ៩ | ទម្រង់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ( ឧបសម្ព័ន្ធទី៤ ) | 28 |


បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# ១- សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមដេញថ្លៃ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខៈ ០៤៦៣៨៣

ថ្ងៃអង្គារ ៨រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាស ឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់ខ្សាច់ទន្លេ ។

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃចន្ទ ទី២៩ ខែមេសា ឆ្នាំ២០២៤ តទៅ រៀងរាល់ម៉ោងធ្វើការ (៨:០០នាទី ដល់១៦:៣០នាទី) ដល់ថ្ងៃ អង្គារ ទី០២ ខែកក្កដា ឆ្នាំ២០២៤ ត្រឹមវេលាម៉ោង ១៦:០០នាទី ក្នុងមួយច្បាប់តម្លៃ ៧០០,០០០រៀល។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃគឺ ថ្ងៃពុធ ទី០៣ ខែកក្កដា ឆ្នាំ២០២៤ វេលាម៉ោង ១៤:០០នាទី នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) អាសយដ្ឋានខាងលើ។

គ្រប់ពាក្យដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសារដេញថ្លៃ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**
**អគ្គនាយកនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**ឡុង ណារ៉ូ**

ចម្លងជូនៈ
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ

# ២- សេចក្ដីណែនាំចំពោះអ្នកដេញថ្លៃ

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# សេចក្ដីណែនាំចំពោះអ្នកដេញថ្លៃ

## ១- វិសាលភាព

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានបំណងដាក់ឲ្យដេញថ្លៃដើម្បីផ្គត់ផ្គង់ខ្សាច់ទន្លេ តាមវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ ដូចមានបរិយាយនៅក្នុងតារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស ក្នុងឯកសារដេញថ្លៃនេះ។

អ្នកដេញថ្លៃឈ្នះនឹងត្រូវធ្វើការផ្គត់ផ្គង់ខ្សាច់ទន្លេ តាមការកំណត់ ដល់ទីតាំងការដ្ឋានដែលទទួលបានការស្នើសុំពីប្រធានការិយាល័យពាក់ព័ន្ធ ឬប្រធានការដ្ឋាន ក្រោយពីកិច្ចសន្យាចូលជាធរមាន។

## ២- ប្រភពឥណទាន

ប្រភពឥណទានសម្រាប់ការផ្គត់ផ្គង់នេះ បានមកពីថវិការបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញឆ្នាំ២០២៤។

## ៣- សិទ្ធិចូលរួមដេញថ្លៃ

ការដេញថ្លៃនេះ បើកចំហចំពោះក្រុមហ៊ុន/សហគ្រាសទាំងអស់ គិតទាំងក្រុមហ៊ុនបរទេស ដែលបានចុះបញ្ជីត្រឹមត្រូវនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែក្រុមហ៊ុន/សហគ្រាសដែលកំពុងស្ថិតក្នុងបញ្ជីខ្មៅ ឬត្រូវបានហាមឃាត់ដោយតុលាការ។

## ៤- សមាសធាតុនៃឯកសារដេញថ្លៃ

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

សមាសធាតុនៃឯកសារដេញថ្លៃរួមមាន៖

១- សេចក្ដីជូនដំណឹងស្ដីពីការអញ្ជើញចូលរួមដេញថ្លៃ
២- សេចក្ដីណែនាំចំពោះអ្នកដេញថ្លៃ
៣- លក្ខខណ្ឌនៃកិច្ចសន្យា
៤- ពាក្យសុំដេញថ្លៃ
៥- តារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស
៦- សេចក្ដីប្រកាសស្ដីពីក្រមសីលធម៌លទ្ធកម្មរបស់អ្នកដេញថ្លៃ
៧- ប៉ាន់គំរូ ឬកាតាឡុក
៨- ទម្រង់លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ
៩- ទម្រង់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

(ចំណុច ៤ ដល់ ៩) "ឧបសម្ព័ន្ធត្រូវបំពេញដោយអ្នកដេញថ្លៃ"

១០- ឯកសារភ្ជាប់បញ្ជាក់លក្ខណសម្បត្តិអ្នកចូលរួមដេញថ្លៃ (មើលប្រការ៥)

អ្នកដេញថ្លៃត្រូវយកចិត្តទុកដាក់ពិនិត្យខ្លឹមសារ និងបំពេញឯកសារដេញថ្លៃឲ្យបានម៉ត់ចត់។ សំណើដេញថ្លៃណាដែលមិនឆ្លើយតបសមស្របតាមការតម្រូវ គឺជាបុព្វបទនៃការពិនិត្យពិចារណាបដិសេធ។

## ៥- ឯកសារភ្ជាប់បញ្ជាក់លក្ខណសម្បត្តិអ្នកចូលរួមដេញថ្លៃ

អ្នកដេញថ្លៃ ត្រូវភ្ជាប់ជាមួយនូវឯកសារភស្តុតាង បង្ហាញពីលក្ខណសម្បត្តិរបស់ខ្លួនដូចខាងក្រោម៖

| | |
|---|---|
| -អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) | ០១ ច្បាប់ (២ច្បាប់ចម្លង) |
| -ប័ណ្ណប៉ាតង់ឆ្នាំដេញថ្លៃ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) | ០១ ច្បាប់ (២ច្បាប់ចម្លង) |
| -វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម អ.ត.ប (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) | ០១ ច្បាប់(២ច្បាប់ចម្លង) |
| -វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) | ០១ ច្បាប់ (២ច្បាប់ចម្លង) |
| -ច្បាប់អនុញ្ញាតអោយធ្វើអាជីវកម្ម ចេញដោយក្រសួងជំនាញពាក់ព័ន្ធ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) | ០១ ច្បាប់ (២ច្បាប់ចម្លង) |
| -វិញ្ញាបនប័ត្រចុះបញ្ជីអ្នកផ្គត់ផ្គង់ទំនិញ ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) | ០១ ច្បាប់ (២ច្បាប់ចម្លង) |
| -ប៉ាន់គំរូ ឬកាតាឡុក (ប្រសិនបើមាន) | ០១ ច្បាប់ (២ច្បាប់ចម្លង) |
| -ឯកសារភស្តុតាងសម្រាប់បញ្ជាក់ពីសមត្ថភាព "ហិរញ្ញវត្ថុ បច្ចេកទេស បទពិសោធន៍" (ចម្លងតាមច្បាប់ដើម) | ០១ ច្បាប់ (២ច្បាប់ចម្លង) |

គ្រប់ឯកសារភ្ជាប់ខាងលើដែលចម្លងត្រឹមត្រូវតាមច្បាប់ដើម ត្រូវមានបញ្ជាក់ពីសាលារាជធានីភ្នំពេញ ឬស្ថាប័នពាក់ព័ន្ធ។

## ៦- សំណើដេញថ្លៃមួយសម្រាប់អ្នកដេញថ្លៃតែមួយគត់

ក្រុមហ៊ុន/សហគ្រាសដែលមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ក្នុងករណីពិនិត្យឃើញថា ក្រុមហ៊ុន/សហគ្រាសដែលបានចូលរួមធ្វើការដេញថ្លៃ ជាក្រុមហ៊ុនមានសម្ពន្ធ័ភាពជាមួយគ្នា ឬមានប្រភពតែមួយ នឹងត្រូវបដិសេធដោយស្វ័យប្រវត្តិ។

## ៧- ភាសា

អ្នកដេញថ្លៃត្រូវបំពេញសំណើដេញថ្លៃជាភាសាខ្មែរ លើកលែងតែពាក្យបច្ចេកទេសខ្លះដែលត្រូវសរសេរជាភាសាបរទេស។ ក្នុងករណីចាំបាច់ អាចសរសេរជាភាសាបរទេសដោយត្រូវបកប្រែចេញពីឯកសារដេញថ្លៃជាភាសាខ្មែរ។ ក្នុងករណី មានខ្លឹមសារមិនស្របគ្នារវាងភាសាខ្មែរ និងភាសាបរទេស ឯកសារដេញថ្លៃជាភាសាខ្មែរ គឺជាឯកសារយោង។

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

## ៨- ពាក្យសុំដេញថ្លៃ

អ្នកដេញថ្លៃត្រូវបំពេញពាក្យសុំដេញថ្លៃ ដែលបញ្ជាក់ពីការប្តេជ្ញាចិត្តគោរពតាមកិច្ចសន្យា បញ្ជាក់ពីការផ្តល់តារាងតម្លៃសមរម្យ ដែលបានផ្តល់នៅក្នុងសំណើដេញថ្លៃ និងកំណត់ពីមុខទំនិញដែលត្រូវផ្គត់ផ្គង់ដោយបរិយាយច្បាស់លាស់ពីលក្ខណៈបច្ចេកទេស ប្រភព គុណភាព តម្លៃ រយៈពេលប្រគល់-ទទួល។ល។

## ៩- រូបិយប័ណ្ណដាក់ដេញថ្លៃ

តម្លៃដាក់ដេញថ្លៃត្រូវជារូបិយប័ណ្ណជាតិគឺ (ប្រាក់រៀល)។ ប្រសិនបើដាក់ជារូបិយប័ណ្ណបរទេស ត្រូវប្តូរជាប្រាក់រៀល តាមអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជានាថ្ងៃបើកសំណើដេញថ្លៃ។

## ១០- ការដាក់តម្លៃដេញថ្លៃ

អ្នកដេញថ្លៃត្រូវពិនិត្យឲ្យបានត្រឹមត្រូវលើតារាងតម្លៃ ដោយពិនិត្យអំពីបរិមាណ តម្លៃឯកតា និងតម្លៃសរុបនៃមុខទំនិញដែលស្នើសុំឲ្យផ្គត់ផ្គង់តាមកិច្ចសន្យា (មើលឧបសម្ព័ន្ធទី២)។

អ្នកដេញថ្លៃត្រូវដាក់តម្លៃដេញថ្លៃតែមួយគត់ ហើយជាតម្លៃថេរក្នុងរយៈពេលអនុវត្តកិច្ចសន្យារបស់ខ្លួន និងមិនមែនជាកម្មវត្ថុសម្រាប់ធ្វើការផ្លាស់ប្តូរទេ។ សំណើដេញថ្លៃណាមួយដែលដាក់តម្លៃដេញថ្លៃលើសពីមួយ ឬតម្លៃប្រែប្រួល ត្រូវចាត់ទុកជាមោឃៈ។ តម្លៃដាក់ស្នើឡើងត្រូវមានទាំងពន្ធ-អាករគ្រប់ប្រភេទ អាករលើតម្លៃបន្ថែម(VAT) ការធានារ៉ាប់រង ការដឹក ជញ្ជូន ការលើកដាក់ទំនិញចូលឃ្លាំង និងការចំណាយផ្សេងៗ មុនពេលប្រគល់ទំនិញ បានន័យថា បានន័យថា "DDP-ដល់ ការដ្ឋាននានាក្នុងនិងជាយរាជធានីភ្នំពេញ តំបន់តាខ្មៅ និងខេត្តកណ្តាល"។

## ១១- ការចំណាយសម្រាប់ការដេញថ្លៃ

អ្នកដេញថ្លៃត្រូវទទួលខុសត្រូវលើរាល់ការចំណាយផ្សេងៗ ដែលទាក់ទិននឹងការរៀបចំ និងការដាក់សំណើដេញថ្លៃរបស់ខ្លួន។

## ១២- សុពលភាពសំណើដេញថ្លៃ

សំណើដេញថ្លៃត្រូវមានសុពលភាព រយៈពេលយ៉ាងតិចហុកសិប(៦០)ថ្ងៃ គិតចាប់ពីថ្ងៃបើកសំណើដេញថ្លៃ។ សំណើដេញថ្លៃដែលមានសុពលភាពខ្លីជាងនេះ នឹងត្រូវបដិសេធ។

ក្នុងករណីចាំបាច់ គណៈកម្មាធិការលទ្ធកម្មអាចស្នើសុំឲ្យអ្នកដេញថ្លៃពន្យារពេលសុពលភាពនៃសំណើដេញថ្លៃតាមរយៈលិខិត ឬទូរសារដល់អ្នកដេញថ្លៃទាំងអស់។ អ្នកដេញថ្លៃអាចបដិសេធសំណើពន្យារពេលនេះ ហើយអាចដកសំណើដេញថ្លៃវិញបាន ដោយមិនមានការខាតបង់ប្រាក់កក់ធានាការដេញថ្លៃរបស់ខ្លួនឡើយ។ ចំណែកអ្នកដេញថ្លៃដែល យល់ព្រមលើសំណើសុំពន្យារពេលនេះ នឹងមិនអនុញ្ញាតឲ្យធ្វើការផ្លាស់ប្តូរសំណើដេញថ្លៃរបស់ខ្លួនឡើយ។

## ១៣- លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ

អ្នកដេញថ្លៃត្រូវកក់ប្រាក់ធានាការដេញថ្លៃ ដែលមានទឹកប្រាក់យ៉ាងតិចចំនួន **២៥០,០០០,០០០រៀល (ពីររយហាសិបលានរៀល)** ទៅក្នុងគណនីប្រាក់កក់ និងប្រាក់តំកល់របស់អគ្គនាយកដ្ឋានរតនាគារជាតិ ឬ រតនាគាររាជធានី -ខេត្ត នៅធនាគារជាតិនៃកម្ពុជា ឬនៅសាខាធនាគារជាតិរាជធានី-ខេត្ត ឬធនាគារពាណិជ្ជដែលបានចុះអនុស្សារណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បន្ទាប់ពីបានកក់ប្រាក់រួច អ្នកដេញថ្លៃត្រូវស្នើសុំអគ្គនាយកដ្ឋានរតនាគារជាតិឬធនាគារពាណិជ្ជដៃគូរនោះ ចេញនូវលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ (មានទម្រង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) ជាលិខិតធានា (Bank Guarantee) ឬ មូលប្បទានប័ត្រចេញ ដោយធនាគារ (Banker's Cheque, Certified Cheque ឬ Cashier's Order) ត្រូវបំពេញថាបើកឲ្យ "រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ" ក្នុងគោលបំណង "ប្រាក់កក់ធានាការដេញថ្លៃ" សម្រាប់ភ្ជាប់ជាមួយសំណើដេញថ្លៃរបស់ខ្លួន។ **លិខិតធានាប្រាក់កក់ធានាការដេញថ្លៃនេះមានសុពលភាព រយៈពេលយ៉ាងតិចសាមសិប(៣០)ថ្ងៃក្រោយសុពលភាពសំណើដេញថ្លៃ។** ក្នុងករណីមានការពន្យារពេលសុពលភាពនៃសំណើដេញថ្លៃ សុពលភាពនៃប្រាក់កក់ធានាការដេញថ្លៃក៏ត្រូវពន្យារពេលស្របគ្នាផងដែរ។

សំណើដេញថ្លៃណាដែលមិនបានភ្ជាប់មកជាមួយនូវលិខិតធានាប្រាក់កក់ខាងលើ ឬបំពេញប្រាក់កក់មិនបានត្រឹមត្រូវ ឬមិនគ្រប់ចំនួនទេនោះនឹងត្រូវចាត់ទុកជាមោឃៈ ឬមិនត្រូវបានជ្រើសរើសមកវាយតម្លៃប្រគល់កិច្ចសន្យាឡើយ។

ក្នុងរយៈពេល៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ បន្ទាប់ពីអ្នកដេញថ្លៃឈ្នះកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា និងបានចុះកិច្ចសន្យាស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការដេញថ្លៃ ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូរពាក់ព័ន្ធដើម្បីបង្វិលប្រាក់កក់ធានាការដេញថ្លៃជូនអ្នកដេញថ្លៃវិញ។

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ចំពោះអ្នកដេញថ្លៃឈ្នះ ប្រាក់កក់នឹងត្រូវបង្វែរជូនវិញ នៅពេលបានបង់ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យារួច។

ប្រាក់កក់នេះនឹងត្រូវរឹបអូសបង្វែរចូលថវិការបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ប្រសិនបើ ៖

-អ្នកដេញថ្លៃដកសំណើរបស់ខ្លួនវិញមុន និងក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ ដែលមិនទាន់ប្រកាសលទ្ធផលជ័យលាភីអ្នកដេញថ្លៃឈ្នះ។

-អ្នកដេញថ្លៃឈ្នះមិនព្រមចុះហត្ថលេខាលើកិច្ចសន្យា ឬមិនព្រមផ្តល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា។

## ១៤- ការចុះហត្ថលេខាលើសំណើដេញថ្លៃ

អ្នកដេញថ្លៃត្រូវរៀបចំសំណើដេញថ្លៃជាបីច្បាប់ (ច្បាប់ដើមមួយច្បាប់ និងច្បាប់ចម្លងពីរច្បាប់)។ ក្នុងករណីមានភាពមិនស្របគ្នារវាងច្បាប់ដើម និងច្បាប់ចម្លងនោះ ច្បាប់ដើមជាឯកសារផ្លូវការ។ ច្បាប់ដើមត្រូវបំពេញដោយដៃ និងប្រើប្រាស់ទឹកខ្មៅដែលមិនអាចលុបជ្រះ ហើយត្រូវចុះហត្ថលេខាដោយអ្នកដេញថ្លៃ ឬអ្នកតំណាងដែលមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវ។ លិខិតផ្ទេរសិទ្ធិនេះ ត្រូវភ្ជាប់មកជាមួយសំណើដេញថ្លៃ។ គ្រប់ទំព័រនៃសំណើដេញថ្លៃ រួមទាំងទំព័រដែលបំពេញបន្ថែម ឬកែតម្រូវ ត្រូវចុះហត្ថលេខាសង្ខេបដោយអ្នកដែលត្រូវចុះហត្ថលេខាលើសំណើដេញថ្លៃ ដើម្បីចៀសវាងការក្លែងបន្លំ។

## ១៥- ការបិទភ្ជិត និងការធ្វើកំណត់សម្គាល់លើសំណើដេញថ្លៃ

ឯកសារច្បាប់ដើម និងច្បាប់ចម្លងត្រូវដាក់ក្នុងស្រោមសំបុត្របីផ្សេងគ្នាបិទភ្ជិត ដោយមានធ្វើសញ្ញាសម្គាល់លើ ស្រោមសំបុត្រថា "ច្បាប់ដើម" និង "ច្បាប់ចម្លង" រួចដាក់ក្នុងស្រោមសំបុត្ររួមធំមួយទៀតបិទភ្ជិត។ លើស្រោមសំបុត្រខាងក្នុង និងខាងក្រៅត្រូវសរសេរថា៖

-មិនត្រូវបើកមើលមុនពេលវេលា និងកាលបរិច្ឆេទកំណត់សម្រាប់ការបើកសំណើដេញថ្លៃ

-ផ្ញើជូនអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (អាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ទូរស័ព្ទលេខ ០១៧ ៨១១ ៩១១)។

-ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ អ៊ីមែល របស់អ្នកដេញថ្លៃ។

ប្រសិនបើស្រោមសំបុត្រណាមួយមិនបានបិទភ្ជិត និងមិនមានធ្វើកំណត់សម្គាល់ដូចការតម្រូវខាងលើទេនោះ គណៈកម្មាធិការលទ្ធកម្មនឹងមិនទទួលខុសត្រូវចំពោះការផ្ញើត្រឡប់ទៅវិញខុសទីកន្លែង និងការបើកមើលមុនឡើយ។

## ១៦- ការកំណត់ពេលដាក់សំណើរដេញថ្លៃ

-អ្នកដេញថ្លៃ ត្រូវប្រគល់សំណើរដេញថ្លៃរបស់ខ្លួន ជូនអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ឲ្យបានមុនពេលវេលា និងកាលបរិច្ឆេទឈប់ទទួលសំណើរដេញថ្លៃ។

-សំណើរដេញថ្លៃណាមួយដែលដាក់ក្រោយពេលវេលា និងកាលបរិច្ឆេទឈប់ទទួលសំណើរដេញថ្លៃនោះនឹងត្រូវបដិសេធ។

-ក្រោយពេលវេលា និងកាលបរិច្ឆេទឈប់ទទួលសំណើរដេញថ្លៃ ការកែតម្រូវរាល់កំហុសឆ្គងក្នុងសំណើរដេញថ្លៃមិនត្រូវបានអនុញ្ញាតឡើយ។

## ១៧- ការផ្លាស់ប្តូរ និងការដកសំណើរដេញថ្លៃ

អ្នកដេញថ្លៃអាចផ្លាស់ប្តូរ ឬដកសំណើរដេញថ្លៃរបស់ខ្លួន មុនបី(០៣)ថ្ងៃ មុនពេលផុតកំណត់កាលបរិច្ឆេទឈប់ទទួលសំណើរដេញថ្លៃ។ ការជូនដំណឹងរបស់អ្នកដេញថ្លៃ ពីការផ្លាស់ប្តូរ ឬដកសំណើរដេញថ្លៃរបស់ខ្លួនត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយត្រូវបោះត្រា កាខ្វង ហើយបញ្ជូនទៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដោយផ្ទាល់ ឬផ្ញើតាមទូរសារ ប៉ុន្តែត្រូវមានចុះហត្ថលេខាជានាអះអាង។ ការដកសំណើរដេញថ្លៃក្នុងរយៈពេលសុពលភាពនៃសំណើរដេញថ្លៃអាចបណ្តាលអោយមានការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ។ មិនអនុញ្ញាតអោយមានការកែប្រែសំណើរដេញថ្លៃណាមួយ បន្ទាប់ពីផុតកាលបរិច្ឆេទឈប់ទទួលសំណើរដេញថ្លៃ។

## ១៨- កិច្ចប្រជុំមុនពេលបើកសំណើរដេញថ្លៃ

អ្នកដេញថ្លៃអាចស្នើសុំការបំភ្លឺអំពីចំណុចខ្លះៗ នៃឯកសារដេញថ្លៃ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ តាមអាសយដ្ឋានដូចបានកំណត់ក្នុងសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ យ៉ាងតិចដប់បួន(១៤)ថ្ងៃ មុនកាលបរិច្ឆេទបើកសំណើរដេញថ្លៃ។

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងឆ្លើយតបជាលាយលក្ខណ៍អក្សរ ទៅគ្រប់អ្នកដេញថ្លៃដែលបានទទួលឯកសារដេញថ្លៃ មិនលើសបី(៣)ថ្ងៃ មុនកាលបរិច្ឆេទបើកសំណើរដេញថ្លៃ។ ការឆ្លើយតបនេះនឹងពិពណ៌នាអំពីសំណួរ ប៉ុន្តែនឹងមិនត្រូវបានបញ្ជាក់អំពីប្រភពសំណួរទេ។

ក្នុងករណីមានចម្ងល់ច្រើនពាក់ព័ន្ធនឹងឯកសារដេញថ្លៃ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាចធ្វើការប្រជុំមុនកាលបរិច្ឆេទបើកសំណើរដេញថ្លៃ ដើម្បីឆ្លើយបំភ្លឺដោយអញ្ជើញអ្នកដេញថ្លៃដែលបានទទួលឯកសារដេញថ្លៃមកចូលរួម។

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

## ១៩- ការបើកសំណើរដេញថ្លៃ

រាល់សំណើរដេញថ្លៃទាំងអស់ត្រូវបើកជាសាធារណៈភ្លាមៗ តាមពេលវេលា កាលបរិច្ឆេទនិងទីកន្លែងដូចបានកំណត់ក្នុងសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ ក្រោមការដឹកនាំរបស់ប្រធានគណៈកម្មាធិការលទ្ធកម្ម ដោយមានការចូលរួមពីសមាជិកគណៈកម្មាធិការលទ្ធកម្ម អ្នកដេញថ្លៃ និងអ្នកពាក់ព័ន្ធដទៃទៀត។ ព័ត៌មានសំខាន់ៗ ដូចជាឈ្មោះអ្នកដេញថ្លៃ ប្រាក់កក់ធានាការដេញថ្លៃ តម្លៃដាក់ដេញថ្លៃសរុប ការបញ្ចុះតម្លៃនានា ការកែប្រែ ឬការដកសំណើវិញ ត្រូវបានប្រកាស អាន បង្ហាញនិងកត់ត្រាច្បាស់លាស់ នៅពេលបើកសំណើរដេញថ្លៃ។ កំណត់ហេតុបើកសំណើរដេញថ្លៃ ត្រូវបានចែកជូនគ្រប់អ្នកចូលរួមទាំងអស់។

ការបើកសំណើរដេញថ្លៃនេះ ពុំមានន័យថាជាការប្រកាសលទ្ធផលឈ្នះ-ចាញ់ឡើយ។ ការកំណត់ឈ្នះ-ចាញ់គឺអាស្រ័យទៅលើការវាយតម្លៃលើសំណើរដេញថ្លៃនីមួយៗ។

## ២០- ការវាយតម្លៃលើសំណើរដេញថ្លៃ

ការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ និងប្រគល់កិច្ចសន្យា ធ្វើឡើងជាសម្ងាត់ និងដោយម៉ត់ចត់ស្របតាមលក្ខខណ្ឌតម្រូវ និងលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងឯកសារដេញថ្លៃ និងផ្អែកលើព័ត៌មានសំខាន់ៗ ក្នុងកំណត់ហេតុស្តីពីការបើកសំណើ

ដេញថ្លៃ។ ចាប់ពីពេលបើកសំណើដេញថ្លៃរហូតដល់ពេលសម្រេចប្រគល់កិច្ចសន្យាជាផ្លូវការ ការទាក់ទងណាមួយរវាងអ្នកដេញថ្លៃ និងគណៈកម្មាធិការលទ្ធកម្មដែលពាក់ព័ន្ធនឹងសំណើដេញថ្លៃ មិនត្រូវបានអនុញ្ញាតឡើយ។

គណៈកម្មាធិការលទ្ធកម្មនឹងពិនិត្យមើលជាបឋមនូវសំណើដេញថ្លៃ ដោយកំណត់ថាតើមានកំហុសក្នុងការគិតលេខនព្វន្តឬទេ? មានលិខិតធានាប្រាក់កក់ធានាដេញថ្លៃត្រឹមត្រូវឬទេ? មានចុះហត្ថលេខាត្រឹមត្រូវ និងថាតើសំណើដេញថ្លៃជាទូទៅបានបំពេញតាមលក្ខខណ្ឌតម្រូវក្នុងឯកសារដេញថ្លៃឬទេ?

ក្នុងករណីដែលមានភាពមិនស្របគ្នារវាងចំនួនជាតួលេខ និងអក្សរ នោះចំនួនដែលសរសេរជាអក្សរចាត់ទុកជាបានការ។

**កំហុសលេខនព្វន្ត នឹងធ្វើការកែតម្រូវលើមូលដ្ឋានដូចខាងក្រោម៖**

-ប្រសិនបើមានភាពមិនស្របគ្នារវាងតម្លៃសរុបដែលបានមកពីការគុណតម្លៃឯកតា និងបរិមាណ នោះតម្លៃឯកតាត្រូវរក្សានៅដដែលដោយធ្វើការកែតម្រូវលើតម្លៃសរុប។

-ប្រសិនបើមានភាពមិនស្របគ្នារវាងតម្លៃដាក់ដេញថ្លៃសរុប និងផលបូកតម្លៃសរុបនីមួយៗ នោះផលបូកតម្លៃសរុបនីមួយៗ ត្រូវរក្សាទុកនៅដដែល ហើយធ្វើការកែតម្រូវលើតម្លៃដាក់ដេញថ្លៃសរុប។

-ប្រសិនបើអ្នកដេញថ្លៃណាមិនព្រមទទួលយកនូវការកែតម្រូវទេ សំណើដេញថ្លៃរបស់អ្នកដេញថ្លៃនោះនឹងត្រូវបដិសេធ។

មុនពេលវាយតម្លៃលម្អិត គណៈកម្មាធិការលទ្ធកម្មនឹងកំណត់ពីការឆ្លើយតបរបស់សំណើនីមួយៗ ទៅនឹងឯកសារដេញថ្លៃ។ សំណើដេញថ្លៃដែលត្រូវបានចាត់ទុកថាបានឆ្លើយតបពេញលេញ គឺជាសំណើដែលឆ្លើយតបគ្រប់លក្ខខណ្ឌដែលមានចែងនៅក្នុងឯកសារដេញថ្លៃ។ គណៈកម្មាធិការលទ្ធកម្មនឹងពិចារណាបដិសេធនូវសំណើដេញថ្លៃណាដែលឆ្លើយតបមិនសមស្រប។ គណៈកម្មាធិការលទ្ធកម្មធ្វើការប្រៀបធៀបសំណើដេញថ្លៃដែលត្រូវបានកំណត់ថាជាសំណើដេញថ្លៃមានការឆ្លើយតបតាមលក្ខខណ្ឌតម្រូវ ដើម្បីធ្វើចំណាត់ថ្នាក់អ្នកដេញថ្លៃនាំមុខ។

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

## ២១- ការត្រួតពិនិត្យលក្ខណសម្បត្តិតាមក្រោយ

មុនសម្រេចប្រគល់កិច្ចសន្យា គណៈកម្មាធិការលទ្ធកម្មនឹងធ្វើការត្រួតពិនិត្យលក្ខណសម្បត្តិតាមក្រោយរបស់អ្នកដេញថ្លៃនាំមុខទី១ ដោយធ្វើការផ្ទៀងផ្ទាត់ឡើងវិញលើឯកសារភស្តុតាងនានា ដើម្បីធានាភាពត្រឹមត្រូវនៃតម្រូវការផ្លូវច្បាប់ តម្រូវការសមត្ថភាព "ហិរញ្ញវត្ថុ បច្ចេកទេស បទពិសោធន៍" ជាមួយនឹងស្ថានភាពជាក់ស្តែងរបស់អ្នកដេញថ្លៃនាំមុខ ដើម្បីធានាការអនុវត្តកិច្ចសន្យា។ ប្រសិនបើអ្នកដេញថ្លៃនាំមុខទី១ មិនមានលក្ខណសម្បត្តិគ្រប់គ្រាន់ គណៈកម្មាធិការលទ្ធកម្មនឹងបដិសេធសំណើដេញថ្លៃនោះ ហើយបន្តធ្វើការត្រួតពិនិត្យលក្ខណសម្បត្តិតាមក្រោយរបស់អ្នកដេញថ្លៃនាំមុខបន្ទាប់ទៀត។

## ២២- លក្ខណៈវិនិច្ឆ័យនៃការសម្រេចប្រគល់កិច្ចសន្យា

គណៈកម្មាធិការលទ្ធកម្មនឹងសម្រេចប្រគល់កិច្ចសន្យាទៅឲ្យអ្នកដេញថ្លៃឈ្នះ ដែលសំណើរបស់អ្នកដេញថ្លៃនោះត្រូវបានវាយតម្លៃថាឆ្លើយតបសមស្រប និងមានតម្លៃទាបជាងគេ ហើយត្រូវបានកំណត់ថាមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការអនុវត្តកិច្ចសន្យា។

## ២៣- សេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា

បន្ទាប់ពីបញ្ចប់ការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ គណៈកម្មាធិការលទ្ធកម្មនឹងចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាឲ្យអ្នកដេញថ្លៃឈ្នះ ដោយចម្លងជូនគ្រប់អ្នកដេញថ្លៃចាញ់ និងផ្សព្វផ្សាយជាសាធារណៈ ព្រមទាំងទុករយៈពេលដប់(១០)ថ្ងៃធ្វើការ ដើម្បីឲ្យអ្នកដេញថ្លៃទាំងនោះជំទាស់តវ៉ាទៅនឹងលទ្ធផលនៃការដេញថ្លៃ មុននឹងអញ្ជើញអ្នកដេញថ្លៃឈ្នះមកចុះហត្ថលេខាលើកិច្ចសន្យា។

## ២៤- បណ្តឹងតវ៉ា

បណ្តឹងតវ៉ាអាចត្រូវបានធ្វើឡើង នៅគ្រប់ដំណាក់កាលនៃដំណើរការកិច្ចលទ្ធកម្ម មុនពេលចុះកិច្ចសន្យា។ បណ្តឹងតវ៉ាដែលបានធ្វើឡើងក្នុងរយៈពេលនៃការវាយតម្លៃសំណើដេញថ្លៃ នឹងមិនត្រូវបានឆ្លើយតបឡើយ។ ការឆ្លើយតបនោះនឹងត្រូវបានធ្វើឡើង បន្ទាប់ពីការវាយតម្លៃបានបញ្ចប់។

បណ្តឹងតវ៉ាត្រូវធ្វើជូនគណៈកម្មាធិការលទ្ធកម្ម ដូចមានឈ្មោះនិងអាសយដ្ឋានក្នុងឯកសារដេញថ្លៃ។ គណៈកម្មាធិការលទ្ធកម្មធ្វើអង្កេតលើមូលដ្ឋាននៃបណ្តឹងតវ៉ានិងធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃធ្វើការ បន្ទាប់ពីបានទទួលបណ្តឹងតវ៉ានោះ លើកលែងតែក្នុងករណីការតវ៉ាទាំងឡាយដែលបានទទួលក្នុងកំឡុងពេលវាយតម្លៃ។

ក្នុងករណីការឆ្លើយតបរបស់គណៈកម្មាធិការលទ្ធកម្ម មិនបំពេញតាមបំណងអ្នកដេញថ្លៃចាញ់ ឬក៏ពុំមានការឆ្លើយតបណាមួយត្រូវបានធ្វើឡើង នោះបណ្តឹងតវ៉ានឹងត្រូវបានបញ្ជូនទៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈធ្វើការឆ្លើយតប ក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃធ្វើការ។ ករណីនេះមិនបណ្តាលឲ្យមានការបាត់បង់សិទ្ធរបស់អ្នកដេញថ្លៃចំពោះបណ្តឹងតវ៉ាបន្តណាមួយផ្សេងទៀតដែលអ្នកដេញថ្លៃអាចជ្រើសរើសនោះទេ។

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

## ២៥- ការចុះហត្ថលេខាលើកិច្ចសន្យា

បន្ទាប់ពីរយៈពេលដប់(១០)ថ្ងៃធ្វើការ នៃការចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា ប្រសិនបើពុំមានការជំទាស់តវ៉ាណាមួយ ឬបន្ទាប់ពីការជំទាស់តវ៉ាទាំងអស់ត្រូវបានដោះស្រាយ គណៈកម្មាធិការលទ្ធកម្មធ្វើការអញ្ជើញអ្នកដេញថ្លៃឈ្នះមកចុះហត្ថលេខាលើកិច្ចសន្យា ដោយភ្ជាប់ជាមួយនូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ក្នុងរយៈពេលយ៉ាងយូរប្រាំពីរ(០៧)ថ្ងៃ។ ក្នុងករណីដែលអ្នកដេញថ្លៃឈ្នះមិនព្រមចុះហត្ថលេខាលើកិច្ចសន្យា ឬពន្យារពេលចុះហត្ថលេខាលើកិច្ចសន្យា ដោយពុំមានមូលហេតុសមស្របនោះ ប្រាក់កក់ធានាការដេញថ្លៃត្រូវបានរឹបអូសបង់ចូលថវិការបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហើយអ្នកដេញថ្លៃនោះត្រូវបានកំណត់ថាជាមុខសញ្ញាសម្រាប់ការចុះឈ្មោះក្នុងបញ្ជីខ្មៅ។ ជាមួយគ្នានេះគណៈកម្មាធិការលទ្ធកម្ម ពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិតាមក្រោយរបស់អ្នកដេញថ្លៃនាំមុខបន្ទាប់។

## ២៦- ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

អ្នកដេញថ្លៃឈ្នះត្រូវកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ដែលមានទឹកប្រាក់ស្មើនឹងដប់(១០)ភាគរយនៃតម្លៃ កិច្ចសន្យាសរុបទៅក្នុងគណនីប្រាក់កក់ និងប្រាក់តំកល់របស់អគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី-ខេត្ត នៅធនាគារជាតិនៃកម្ពុជា ឬនៅសាខាធនាគារជាតិរាជធានី-ខេត្ត ឬធនាគារពាណិជ្ជដែលបានចុះអនុស្សារណៈយោគយល់គ្នា ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បន្ទាប់ពីបានកក់ប្រាក់រួច អ្នកដេញថ្លៃឈ្នះត្រូវស្នើសុំអគ្គនាយកដ្ឋានរតនាគារជាតិឬធនាគារពាណិជ្ជដៃគូរនោះ ចេញនូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា (មានទម្រង់ និងខ្លឹមសាដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) ជា លិខិតធានា (Bank Guarantee) ឬ មូលប្បទានប័ត្រ ចេញដោយធនាគារ (Banker's Cheque, Certified Cheque ឬ Cashier's Order) ត្រូវបំពេញថាបើកឲ្យ "រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ" ក្នុងគោលបំណង "ប្រាក់កក់ធានាការអនុវត្ត កិច្ចសន្យា" រួចប្រគល់ជូន "អ្នកទិញ" មុនពេលចុះកិច្ចសន្យា។

ការខកខានក្នុងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា គឺជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ។

ក្នុងរយៈពេល៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ បន្ទាប់ពីការប្រគល់ទទួលទំនិញគ្រប់ចំនួន ឬបន្ទាប់ពីផុតរយៈពេលធានាគុណភាពទំនិញ ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូពាក់ព័ន្ធដើម្បី បង្វិលប្រាក់កក់ជូនអ្នកផ្គត់ផ្គង់វិញ។

ក្នុងករណី "អ្នកផ្គត់ផ្គង់" មិនបានអនុវត្តតាមប្រការណាមួយនៃកិច្ចសន្យា ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យានេះនឹងត្រូវរឹបអូសជាថវិការបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហើយនឹងត្រូវបានកំណត់ថាជាមុខសញ្ញាសម្រាប់ការចុះឈ្មោះក្នុងបញ្ជីខ្មៅ។

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# ៣- លក្ខខណ្ឌនៃកិច្ចសន្យា

# លក្ខខណ្ឌនៃកិច្ចសន្យា

## ១- និយមន័យ

-រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ជាអ្នកទិញ ហៅកាត់ថា ភាគី "ក" តំណាងដោយ **ឯកឧត្តម ឡុង ណារ៉ូ** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម មានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ទូរស័ព្ទលេខ ០១៧ ៨១១ ៩១១។

-ក្រុមហ៊ុន/សហគ្រាស........................... ដែលបានចូលរួមដេញថ្លៃ ហើយដែលត្រូវបានជ្រើសរើសប្រគល់កិច្ចសន្យាស្តីពីការផ្គត់ផ្គង់............................ ជាអ្នកផ្គត់ផ្គង់ ហៅកាត់ថា ភាគី "ខ" តំណាងដោយ.................... មុខងារ.................... អាសយដ្ឋាន................ លេខទូរស័ព្ទ............ អ៊ីមែល...........។

-ការផ្គត់ផ្គង់.................................... ចំនួន ..........។

-តម្លៃឯកតាគឺ................/.....។

-តម្លៃសរុបនៃការផ្គត់ផ្គង់...............( ជាអក្សរ......... ) ដែលចុះកិច្ចសន្យាហៅថា "តម្លៃកិច្ចសន្យា"។

កិច្ចសន្យានេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាទៅរហូតអស់បរិមាណទំនិញ។

DDP-ដល់ការដ្ឋាននានាក្នុងនិងជាយរាជធានីភ្នំពេញ តំបន់តាខ្មៅ និង ខេត្តកណ្តាល ដោយរួមបញ្ចូលទាំងពន្ធ-អាករគ្រប់ប្រភេទព្រមទាំងអាករលើតម្លៃបន្ថែម(VAT)។

## ២- ការបរិយាយ និង លក្ខណៈបច្ចេកទេសទំនិញ

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ទំនិញដែលត្រូវធ្វើការផ្គត់ផ្គង់តាមកិច្ចសន្យានេះ គឺជាទំនិញដែលបានបរិយាយនៅក្នុងតារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស។

## ៣- ការវេចខ្ចប់ ដឹកជញ្ជូន និងលើកដាក់

ភាគី"ខ"ត្រូវមានគ្រឿងចក្រប្រើប្រាស់ប្រកបដោយគុណភាព ដោយមានក្រណាត់កៅស៊ូគ្របអោយជិតដើម្បីធានាបាននូវការដឹកជញ្ជូន កុំអោយប៉ះពាល់ដល់បរិស្ថានក្នុងពេលដឹកជញ្ជូនក៏ដូចជាក្នុងការផ្គត់ផ្គង់ នៅតាមទីតាំងដែលចង្អុលបង្ហាញដោយប្រធានការដ្ឋាន តាមទីតាំងនីមួយៗ ស្របតាមការណែនាំរបស់សាលារាជធានីភ្នំពេញ ឬ អាជ្ញាធរមូលដ្ឋានដោយអនុវត្តតាមលក្ខណៈបច្ចេកទេសនៃការដឹកជញ្ជូន មិនសើម មិនហូរទឹក មិនហុយ និងមិនជ្រុះធ្លាក់ មកលើថ្នល់ដើម្បីការពារបរិស្ថានឲ្យបានល្អ។

ភាគី"ខ"ត្រូវធ្វើការវេចខ្ចប់ទំនិញតាមការតម្រូវ ដើម្បីទប់ស្កាត់ការខូចខាត ឬការថយចុះគុណភាព មុនពេលប្រគល់-ទទួល។

រាល់ច្បាប់អនុញ្ញាតដឹកជញ្ជូនឆ្លងកាត់រាជធានីភ្នំពេញ និង ខេត្តកណ្តាល ជាបន្ទុករបស់ភាគី"ខ"។

## ៤- ការប្រគល់-ទទួល

ភាគី"ខ"ត្រូវផ្គត់ផ្គង់ជូនភាគី"ក"តាមការកំណត់ ដល់ទីតាំងការដ្ឋានដែលទទួលបានការស្នើសុំពីប្រធានការិយាល័យពាក់ព័ន្ធ ឬប្រធានការដ្ឋាន ក្រោយពីកិច្ចសន្យាចូលជាធរមាន។

ការប្រគល់-ទទួលត្រូវតែធ្វើអោយបានម៉ត់ចត់រវាងអ្នកប្រគល់ និងអ្នកទទួលដោយមានបង្កាន់ដៃត្រឹមត្រូវ និងមានចុះហត្ថលេខានៅលើបង្កាន់ដៃប្រគល់-ទទួលឱ្យបានច្បាស់លាស់។ ការប្រគល់-ទទួលនេះធ្វើឡើងដោយមានកំណត់ហេតុប្រគល់-ទទួល ពីតំណាង ភាគី"ក" និងភាគី"ខ" ដោយមានការយល់ព្រមពីគណៈកម្មាធិការលទ្ធកម្ម។

ការធ្វើសំណើសុំទូទាត់ ត្រូវប្រៀបធៀបបង្កាន់ដៃនៃការប្រគល់-ទទួល អោយមានចំនួនស្មើគ្នាដោយភ្ជាប់មកជាមួយនូវតារាងសរុបប្រគល់-ទទួល និងប័ណ្ណប្រគល់ ចុះហត្ថលេខារវាងអ្នកប្រើប្រាស់ និងអ្នកផ្គត់ផ្គង់។

ការប្រគល់-ទទួលត្រូវមានការចូលរួមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៥- ការធានាគុណភាពទំនិញ

ភាគី"ខ"ត្រូវធានាថា រាល់គុណភាពទំនិញត្រូវឆ្លើយតបទៅនឹងប៉ាន់គំរូ កាតាឡុក និងធានាថាទំនិញដែលប្រគល់ ជាទំនិញដែលមានលក្ខណៈបច្ចេកទេសស្របតាមលក្ខខណ្ឌដែល ភាគី"ក"បានកំណត់។ ភាគី"ខ"យល់ព្រមផ្លាស់ប្តូរជំនួស ឬកែតម្រូវដោយចំណាយផ្ទាល់ខ្លួន ចំពោះមុខទំនិញដែលខូចខាត ឬផ្នែកណាមួយនៃទំនិញ ក្រោយពីភាគី"ក"បានប្រាប់

ឲ្យដឹងអំពីលក្ខណៈនៃការខូចខាតនោះ។ ប្រសិនបើភាគី"ខ"ខកខានមិនបានសងការខូចខាត ឬជំនួសទេនោះ ភាគី"ក"អាចចាត់វិធានការចាំបាច់ គឺទិញពីអ្នកផ្សេងទៀត ដែលការចំណាយជាបន្ទុករបស់ភាគី"ខ" ដោយមិនធ្វើឲ្យខូចខាតដល់សិទ្ធិណាមួយរបស់ភាគី"ក" ដែលមាននៅក្នុងកិច្ចសន្យា។ ករណីមានការធានាលើសេវាប្រើប្រាស់ ត្រូវចែងឲ្យបានច្បាស់ក្នុង កិច្ចសន្យា។

## ៦- ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

ភាគី"ខ" ត្រូវកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ដែលមានទឹកប្រាក់ស្មើនឹងដប់(១០)ភាគរយនៃតម្លៃកិច្ចសន្យាសរុប ទៅក្នុងគណនីប្រាក់កក់ និងប្រាក់តំកល់របស់អគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី-ខេត្ត នៅធនាគារជាតិនៃកម្ពុជា ឬនៅសាខាធនាគារជាតិរាជធានី-ខេត្ត ឬធនាគារពាណិជ្ជដែលបានចុះអនុស្សារណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បន្ទាប់ពីបានកក់ប្រាក់រួច អ្នកដេញថ្លៃឈ្នះត្រូវស្នើសុំអគ្គនាយកដ្ឋានរតនាគារជាតិឬធនាគារពាណិជ្ជដៃគូរនោះ ចេញនូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា (មានទម្រង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) ជា លិខិតធានា (Bank Guarantee) ឬ មូលប្បទានប័ត្រ ចេញដោយធនាគារ (Banker's Cheque, Certified Cheque ឬ Cashier's Order) ត្រូវបំពេញថាបើកឲ្យ "រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ" ក្នុងគោលបំណង "ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា" រួចប្រគល់ជូន ភាគី"ក" មុនពេលចុះកិច្ចសន្យា។

ការខកខានក្នុងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា គឺជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ។

ក្នុងរយៈពេល៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ បន្ទាប់ពីការប្រគល់ទទួលទំនិញគ្រប់ចំនួន ឬបន្ទាប់ពីផុតរយៈពេលធានាគុណភាពទំនិញ ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ឬធនាគារពាណិជ្ជដៃគូពាក់ព័ន្ធដើម្បី បង្វិលប្រាក់កក់ជូនអ្នក ភាគី"ខ"វិញ។

ក្នុងករណី ភាគី"ខ" មិនបានអនុវត្តតាមប្រការណាមួយនៃកិច្ចសន្យា ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យានេះនឹងត្រូវរឹបអូសបង់ចូលថវិការបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហើយនឹងត្រូវបានកំណត់ថាជាមុខសញ្ញាសម្រាប់ការចុះឈ្មោះក្នុងបញ្ជីខ្មៅ។

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

## ៧- ការកែប្រែបញ្ជាទិញ

-ប្រសិនបើភាគី"ក"មានបំណងផ្លាស់ប្តូរការបញ្ជាទិញ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគី"ខ" និងត្រូវប្រជុំដោះស្រាយការកែប្រែលើកិច្ចសន្យា។ ការកែប្រែអាចធ្វើឡើងក្នុងលក្ខណៈបច្ចេកទេស បរិមាណ និងទីកន្លែងប្រគល់-ទទួល។

-ប្រសិនបើភាគី"ខ"ទទួលយកនូវការកែប្រែនេះតាមលក្ខខណ្ឌដែលបានព្រមព្រៀងនោះ ការកែប្រែនឹងក្លាយទៅជាឯកសារឧបសម្ព័ន្ធបន្ថែមនៃកិច្ចសន្យា។ ការកែប្រែត្រូវមានការឯកភាពជាចុងក្រោយពីប្រធានគណៈកម្មាធិការលទ្ធកម្ម។

-ការកែប្រែបញ្ជាទិញត្រូវមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៨- ការត្រួតពិនិត្យ និងការសាកពិសោធន៍

ប្រសិនបើភាគី"ក"ចាត់ទុកថាការសាកពិសោធន៍ ឬការត្រួតពិនិត្យជាការចាំបាច់នោះ ក្នុងកិច្ចសន្យាត្រូវមានបញ្ជាក់ ពីចំណុចស្តីពីការសាកពិសោធន៍ ឬការត្រួតពិនិត្យ ដោយបញ្ជាក់ពីទីកន្លែង និងពេលវេលាច្បាស់លាស់។

ភាគី"ខ"ត្រូវបង្កភាពងាយស្រួលក្នុងការផ្តល់ប៉ាន់គំរូ កាតាឡុក ទិន្នន័យនៃផលិតផល លិខិតធានាផ្សេងៗ ដើម្បីឲ្យដំណើរការសាកពិសោធន៍ ឬការត្រួតពិនិត្យប្រព្រឹត្តទៅបានឆាប់រហ័ស ដោយមិនគិតសោហ៊ុយចំណាយពីភាគី"ក"បន្ថែមទៀតឡើយ។ ប្រសិនបើទំនិញដែលបានត្រួតពិនិត្យ ឬសាកពិសោធន៍ឃើញថាមិនសមស្របតាមលក្ខណៈបច្ចេកទេសនោះ ភាគី"ក"អាចបដិសេធ ហើយភាគី"ខ"ចាំបាច់ត្រូវធ្វើការកែតម្រូវតាមលក្ខណៈបច្ចេកទេសដែលបានកំណត់ ហើយសោហ៊ុយចំណាយជាបន្ទុករបស់ភាគី"ខ"។

## ៩- ការពន្យារពេលផ្គត់ផ្គង់

ភាគី"ខ"អាចស្នើសុំពន្យារពេលផ្គត់ផ្គង់បាន ដោយមានការយល់ព្រមពីភាគី"ក" ផ្អែកលើមូលហេតុជាក់ស្តែង។ ភាគី"ខ"ត្រូវជូនដំណឹងពីរាល់ព្រឹត្តិការណ៍ដែលបណ្តាលឲ្យមានការយឺតយ៉ាវ ហើយភាគី"ក"ត្រូវពិនិត្យនិងសម្រេចលើការសុំពន្យារពេលផ្គត់ផ្គង់ មិនឲ្យលើសពីប្រាំពីរ(០៧)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតស្នើសុំរបស់ភាគី"ខ"។ ប្រសិនបើភាគី"ខ" ខកខានក្នុងការប្រកាសជូនដំណឹងជាមុនអំពីការយឺតយ៉ាវ ឬខកខានក្នុងការធ្វើកិច្ចសហការ ដើម្បីដោះស្រាយការយឺតយ៉ាវនោះ ការយឺតយ៉ាវបែបនេះមិនត្រូវបានពិចារណាដើម្បីផ្តល់ការពន្យារពេលបន្ថែមឡើយ។

ការពន្យាពេលផ្គត់ផ្គង់ត្រូវមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ១០- ករណីប្រធានសក្តិ

ក្នុងករណីប្រធានសក្តិ ដូចជាភ្លើងឆេះ ទឹកជំនន់ រញ្ជួយផែនដី ជម្ងឺរាលដាល បាតុកម្ម កុបកម្ម ទណ្ឌកម្មសេដ្ឋកិច្ច និងវិបត្តិភ័យដទៃទៀត ឬព្រឹត្តិការណ៍ដែលធ្វើឲ្យភាគី"ខ"មានការលំបាកខ្លាំងក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមពេល កំណត់ ភាគី"ខ"ត្រូវផ្តល់ព័ត៌មានជូនភាគី"ក"ឲ្យបានឆាប់តាមតែអាចធ្វើបាន ដើម្បីស្វែងរកដំណោះស្រាយ។

ប្រសិនបើភាគី"ខ"មិនបានផ្តល់ព័ត៌មានឲ្យបានទាន់ពេលវេលាទេ នោះភាគី"ក"នឹងមិនទទួលខុសត្រូវចំពោះបញ្ហានេះឡើយ។

ការយឺតយ៉ាវ ឬខកខានក្នុងការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា ដែលបណ្តាលពីករណីប្រធានសក្តិនេះ ភាគី"ខ" មិនត្រូវបានទទួលរងនូវការផាកពិន័យ ឬរឹបអូសប្រាក់កក់ធានាការអនុវត្តឡើយ។

## ១១- កិច្ចសន្យាបន្ត

ការចុះកិច្ចសន្យាបន្តនៃកិច្ចសន្យាទាំងមូលមិនត្រូវបានអនុញ្ញាតជាដាច់ខាត។ ភាគី"ខ"អាចចុះកិច្ចសន្យាបន្តអោយ "ភាគីផ្គត់ផ្គង់បន្ត" ដើម្បីអោយអនុវត្តផ្នែកណាមួយនៃកិច្ចសន្យាបាន ដរាបណាមានការយល់ព្រមពី ភាគី"ក"។ "ភាគីផ្គត់ផ្គង់បន្ត" ត្រូវចុះកិច្ចសន្យាជាមួយភាគី"ខ" មិនមែនចុះកិច្ចសន្យាជាមួយភាគី"ក"នោះទេ។ ប្រសិនបើ "ភាគីផ្គត់ផ្គង់បន្ត" មានកំហុសឆ្គងណាមួយ ភាគី"ខ"ត្រូវទទួលខុសត្រូវទាំងស្រុង ដោយធានាថាកំហុសទាំងនោះត្រូវបានកែតម្រូវ។ ភាគី"ក" មិនធ្វើការដោះស្រាយបញ្ហាណាមួយដោយផ្ទាល់ជាមួយ "ភាគីផ្គត់ផ្គង់បន្ត" ឡើយ។

កិច្ចសន្យាបន្តត្រូវមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ១២- ការបញ្ចប់កិច្ចសន្យា

ភាគី"ក"អាចពិចារណាលុបចោលកិច្ចសន្យាទាំងមូល ឬផ្នែកខ្លះ តាមកាលៈទេសៈដូចខាងក្រោម៖

១-ប្រសិនបើភាគី"ខ" មិនមានលទ្ធភាពប្រគល់នូវមុខទំនិញតាមកាលកំណត់ដូចមានចែងក្នុងកិច្ចសន្យា

២-ប្រសិនបើភាគី"ខ" មិនអាចបំពេញកាតព្វកិច្ចរបស់ខ្លួនតាមលក្ខខណ្ឌនៃកិច្ចសន្យា

៣-ប្រសិនបើភាគី"ខ" ក្ស័យធន ឬក៏ស្ថិតក្នុងស្ថានភាពក្ស័យធន ដែលមិនអាចសងបំណុលគេបាន

ក្នុងករណីដែលភាគី"ក"បញ្ចប់កិច្ចសន្យាតាមចំណុចទី១ឬទី២ខាងលើ នោះភាគី"ក"អាចទិញទំនិញដែលខកខានមិនបានប្រគល់ ប្រសិនបើខ្លួនគិតថាចាំបាច់ ហើយភាគី"ខ"ត្រូវទទួលខុសត្រូវចំពោះការចំណាយលើការទិញទំនិញដែលមិនបានប្រគល់នោះ។ ក្នុងករណីដែលបញ្ចប់កិច្ចសន្យាដោយហេតុផលក្ស័យធន ការបញ្ចប់កិច្ចសន្យានឹងមិនប៉ះពាល់ដល់សិទ្ធិឬសកម្មភាពណាមួយរបស់ភាគី"ក"ឡើយ។

ការបញ្ចប់កិច្ចសន្យាត្រូវមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ១៣- ការទូទាត់

ការទូទាត់អាចធ្វើឡើងជាដំណាក់កាលៗ តាមលទ្ធផលប្រគល់-ទទួលជាក់ស្តែង ដោយមានកំណត់ហេតុប្រគល់-ទទួល ច្បាស់លាស់។

ភាគី"ខ" អាចធ្វើសំណើសុំទូទាត់រៀងរាល់ខែដោយមិនឲ្យហួសពីសប្តាហ៍ទី១នៃខែបន្ទាប់តាមបរិមាណជាក់ស្តែង ដោយធ្វើការផ្ទៀងផ្ទាត់នឹងបង្កាន់ដៃនៃការប្រគល់-ទទួល ត្រូវតែមានចំនួនស្មើគ្នា ដោយភ្ជាប់មកជាមួយនូវតារាងសរុបប្រគល់-

ទទួលដែលមានការចុះហត្ថលេខារវាងអ្នកប្រើប្រាស់ និងអ្នកផ្គត់ផ្គង់ នឹងត្រូវបញ្ជូនមកអង្គភាពលទ្ធកម្ម ដើម្បីរៀបចំសំណើរសុំទូទាត់ ទៅនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ។

រូបិយវត្ថុសម្រាប់ធ្វើការទូទាត់គឺ ប្រាក់រៀល។ ការទូទាត់ត្រូវធ្វើឡើងតាមរយៈ៖

-អគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ......... ដោយបង្វែរចូលគណនីរបស់ភាគី"ខ" លេខ............... នៅធនាគារ................ ក្នុងរយៈពេលយ៉ាងយូរសែសិបប្រាំ(៤៥)ថ្ងៃ ក្រោយការប្រគល់-ទទួល។ ឬ

-ម្ភៃមួយ(២១)ថ្ងៃ តាមរយៈ៖

+ការផ្ទេរសាច់ប្រាក់

-ឈ្មោះធនាគារ ..................................

-ឈ្មោះអ្នកទទួល ..................................

-លេខគណនី .................................. ឬ

+មូលប្បទានប័ត្រ

-បើកឲ្យឈ្មោះ ..................................។

**១៤- ពន្ធ អាករ**

ភាគី"ខ"ត្រូវបង់ជូនរដ្ឋនូវពន្ធ-អាករគ្រប់ប្រភេទ រួមទាំង"អាករលើតម្លៃបន្ថែម" តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ "អាករលើតម្លៃបន្ថែម" ត្រូវបង់តាម "វិធីកាត់ទុក" ដោយអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ... នាពេលទូទាត់រហូតអស់តម្លៃកិច្ចសន្យា។

**១៥- ការផាកពិន័យ**

ក្នុងករណីភាគី"ខ"មិនបានប្រគល់នូវមុខទំនិញតាមពេលកំណត់ នោះភាគី"ខ"ត្រូវទទួលរងនូវការផាកពិន័យជាប្រាក់ចំនួនសូន្យក្បៀសមួយភាគរយ 0,10% ក្នុងមួយថ្ងៃ នៃតម្លៃទំនិញដែលប្រគល់យឺតយ៉ាវ តាមចំនួនថ្ងៃដែលយឺតយ៉ាវនោះ។ ចំនួនទឹកប្រាក់ពិន័យនេះ មិនត្រូវឲ្យលើសពីដប់ភាគរយ 10% នៃតម្លៃកិច្ចសន្យាទេ នៅពេលដែលចំនួនទឹកប្រាក់ពិន័យលើសកម្រិតអតិបរមានេះ ភាគី"ក"អាចពិចារណាពីការលុបកិច្ចសន្យា។

ក្នុងករណីដែលភាគី"ក" ធ្វើការទូទាត់យឺតយ៉ាវ នោះភាគី"ក" ត្រូវរងការពិន័យជាប្រាក់ជូន ភាគី"ខ"ចំនួនសូន្យក្បៀសសូន្យប្រាំភាគរយ 0,05% ក្នុងមួយថ្ងៃ លើចំនួនទឹកប្រាក់ដែលត្រូវទូទាត់តាមចំនួនថ្ងៃដែលយឺតយ៉ាវនោះ។

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

**១៦- ការទប់ទល់នឹងលាភសក្ការៈ**

ភាគី"ខ"ត្រូវប្រកាសអះអាងថាខ្លួនពុំបានផ្តល់ឬសន្យានឹងផ្តល់ប្រាក់ចំណាយឬលាភសក្ការៈណាមួយចំពោះមន្ត្រីនិយោជិតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញណាមួយ ឬអ្នកដេញថ្លៃណាមួយ ដើម្បីទទួលបានកិច្ចសន្យា ហើយសកម្មភាពទាំងនេះគឺជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់ផ្អាក ឬលុបកិច្ចសន្យា។

**១៧- ការដោះស្រាយវិវាទ**

កិច្ចសន្យានេះត្រូវគ្រប់គ្រង និងត្រូវបកស្រាយតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ជម្លោះណាមួយដែលកើតឡើងរវាងភាគីទាំងពីរអំពីលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាឬទាក់ទិននឹងការអនុវត្តកិច្ចសន្យា ត្រូវដោះស្រាយតាមការសម្របសម្រួលជាមុនរវាងភាគីទាំងពីរ។ ប្រសិនបើបរាជ័យ នោះភាគីទាំងពីរត្រូវយល់ព្រមដោះស្រាយតាមរយៈមេធាវីដោយភាគីទាំងពីរមានសិទ្ធិជ្រើសតាំងមេធាវីម្នាក់មួយ ហើយអាជ្ញាកណ្តាលមួយរូបនឹងត្រូវតែងតាំងដោយមានការយល់ព្រមរវាងភាគីទាំងពីរ។ បើភាគីទាំងពីរមិនយល់ស្របគ្នាលើការតែងតាំង ឬមិនឯកភាពតាមការសម្រេចរបស់អាជ្ញាកណ្តាលនោះត្រូវដោះស្រាយវិវាទតាមផ្លូវតុលាការនៃព្រះរាជាណាចក្រកម្ពុជា។

**១៨- សោហ៊ុយទាក់ទងរឿងក្តី**

ក្នុងករណីមានរឿងក្តីក្តាំកើតឡើង ដែលបណ្តាលមកពីភាគី"ខ"រំលោភលើលក្ខខណ្ឌនានានៃកិច្ចសន្យា ភាគី"ខ"ត្រូវទទួលខុសត្រូវចំពោះភាគី"ក"រាល់ការចំណាយក្នុងការជួលមេធាវី។ ការចំណាយលើការខូចខាត និងចំណាយផ្សេងទៀតក្នុងរឿងក្តីនោះ ត្រូវកំណត់ដោយច្បាប់។

**១៩- ការប្រើប្រាស់ឯកសារកិច្ចសន្យា**

ប្រសិនបើគ្មានការយល់ព្រមពីភាគី"ក" នោះភាគីភាគី"ខ"មិនត្រូវប្រើប្រាស់ឯកសារកិច្ចសន្យា ឬ មិនត្រូវបង្ហាញ ឬ ផ្តល់ព័ត៌មានដែលមាននៅក្នុងឯកសារកិច្ចសន្យាឲ្យអ្នកដទៃដឹងឡើយ លើកលែងតែប្រើប្រាស់ក្នុងបំណងអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យា។

ថ្ងៃ..........ខែ..........ឆ្នាំ..........ស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..........ឆ្នាំ២០២៤

**ប្រធានអង្គភាពលទ្ធកម្ម**

ស៊ឹម វល្លិកា

បានឃើញ និង ឯកភាព

ថ្ងៃ..........ខែ..........ឆ្នាំ..........ស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី...០១......ខែមេសា..ឆ្នាំ២០២៤

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**
**អគ្គនាយកនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**ឡុង ណារ៉ូ**

**ទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

លេខ:..................១០៣..........................សហវ-អលស្វា

ថ្ងៃ..........ខែ..........ឆ្នាំ..........ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..........ឆ្នាំ២០២៤

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ**

ឈឹម សារ៉េត

# ៤- ពាក្យសុំដេញថ្លៃ

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# ពាក្យសុំដេញថ្លៃ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................................... ភេទ...................... សញ្ជាតិ......................... ថ្ងៃ ខែ ឆ្នាំកំណើត.............................................. ទីកន្លែងកំណើត............................................................... មុខងារ............................................ តំណាងក្រុមហ៊ុន/សហគ្រាស........................................................... ដែលមានអាសយដ្ឋាន............................................................................ ទូរស័ព្ទ................................... ទូរសារ/អ៊ីមែល................................................. គេហទំព័រ..................................................។

**សូមគោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**
**អគ្គនាយកនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**កម្មវត្ថុ:** សំណើសុំចូលរួមដេញថ្លៃការផ្គត់ផ្គង់................................................................................................................................................................................។

**យោង:** សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់................................................................................................................................................................................................................................................................។

បានពិនិត្យត្រឹមត្រូវ

សេចក្តីដូចមានក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រតិភូ** ជ្រាបថា ខ្ញុំបាទ/នាងខ្ញុំមានបំណងចូលរួមដេញថ្លៃការផ្គត់ផ្គង់.................................................................................................................................ដោយដាក់តម្លៃដេញថ្លៃសរុបចំនួន.........................................................រៀល (សរសេរជាអក្សរ .............................................................................................................................................................រៀល)។ ចំនួនទឹកប្រាក់នេះមានបញ្ជាក់លម្អិតក្នុងតារាងតម្លៃ ដែលបានភ្ជាប់មកជាមួយ។

សំណើដេញថ្លៃរបស់ខ្ញុំបាទ/នាងខ្ញុំមានសុពលភាព រយៈពេល ..............(..............................)ថ្ងៃ បន្ទាប់ពីថ្ងៃបើកសំណើដេញថ្លៃ។

ប្រសិនបើសំណើដេញថ្លៃរបស់ខ្ញុំបាទ/នាងខ្ញុំបានទទួលជោគជ័យនោះ ខ្ញុំបាទ/នាងខ្ញុំនឹងបំពេញតាមគ្រប់នីតិវិធី ដែលបានកំណត់ ព្រមទាំងគោរពឲ្យបានពេញលេញនូវលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា។

សូម **ឯកឧត្តមប្រតិភូ** ទទួលនូវក្តីគោរពអំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ..................................ខែ..............ឆ្នាំ....................... ព.ស.២៥៦...
រាជធានីភ្នំពេញ ថ្ងៃទី.............ខែ................ឆ្នាំ២០២៤
**ហត្ថលេខា ត្រា និងឈ្មោះអ្នកដេញថ្លៃ**

បានពិនិត្យត្រឹមត្រូវ
អង្គភាពលទ្ធកម្មសាធារណៈ

# ៥- តារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស

# តារាងតម្លៃ និងបញ្ជាក់លក្ខណៈបច្ចេកទេស
## ស្តីពី
## ការផ្គត់ផ្គង់ខ្សាច់ទន្លេ

| ល.រ | រាយមុខទំនិញ និងបញ្ជាក់លក្ខណៈបច្ចេកទេស | ឯកតា | បរិមាណ | តម្លៃឯកតា | តម្លៃសរុប | ប្រភព |
|---|---|---|---|---|---|---|
| 1 | ខ្សាច់ទន្លេ | ម៉ែត្រគូប | 250,000 | | | កម្ពុជា |
| **សរុប** | | | | | | |

បញ្ឈប់ទឹកប្រាក់ត្រឹមចំនួន ៖.......................................................................................................................រៀល។

សរសេរជាអក្សរ ៖.................................................................................................................................... រៀល។

បានពិនិត្យត្រឹមត្រូវ
អង្គភាពយកដ្ឋានលទ្ធកម្មសាធារណៈ

-រយៈពេលផ្គត់ផ្គង់ ៖ ជាដំណាក់ៗ តាមតម្រូវការជាក់ស្តែងរហូតអស់បរិមាណទំនិញ។

-ពន្ធអាករ ៖ រាល់ពន្ធ-អាករគ្រប់ប្រភេទជាបន្ទុករបស់ "អ្នកផ្គត់ផ្គង់"។

-អ្នកដេញថ្លៃត្រូវដាក់តម្លៃស្នើសុំផ្គត់ផ្គង់រួមមានទាំងពន្ធ-អាករគ្រប់ប្រភេទ អាករលើតម្លៃបន្ថែម(VAT) ការដឹកជញ្ជូន និងការចំណាយផ្សេងៗដល់ការដ្ឋាននានាក្នុងនិងជាយរាជធានីភ្នំពេញ តំបន់តាខ្មៅ និងខេត្តកណ្ដាល"។

ថ្ងៃ..................................ខែ..............ឆ្នាំ................ស័ក ព.ស.២៥៦...

រាជធានីភ្នំពេញ ថ្ងៃទី..............ខែ................ឆ្នាំ២០២៤

**ហត្ថលេខា ត្រា និងឈ្មោះអ្នកដេញថ្លៃ**

| | |
|---|---|
| | **លក្ខណៈបច្ចេកទេស**<br>**របស់**<br>**ការផ្គត់ផ្គង់ខ្សាច់ទន្លេ** |

ខ្សាច់ទន្លេដែលត្រូវផ្គត់ផ្គង់មានលក្ខណៈបច្ចេកទេសដូចខាងក្រោម ៖

| **លក្ខណៈបច្ចេកទេសស្នើដោយ "អ្នកទិញ"** | **លក្ខណៈបច្ចេកទេសផ្តល់ដោយ "អ្នកផ្គត់ផ្គង់"** |
|---|---|
| -ជាខ្សាច់ក្នាតមានប្រភពពីទន្លេ<br>-មានទំហំចាប់ពី ១មម ទៅ ៥មម<br>-មិនត្រូវមានសំរាមនៅលាយឡំជាមួយឡើយ<br>-មិនត្រូវឲ្យមានដុំថ្ម ឬ លោហៈធាតុ ចាប់ពីទំហំ ៣០មម ឡើងទៅ នៅលាយឡំក្នុងខ្សាច់ឡើយ<br>-មិនត្រូវឲ្យមានដី ឬ ធូលីលាយឡំក្នុងខ្សាច់លើសពី ១០% (ម៉ាស) ឡើយ។ | បានពិនិត្យត្រឹមត្រូវ<br>អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ |

**សម្គាល់:** អ្នកដេញថ្លៃត្រូវបំពេញក្នុងតារាងលក្ខណៈបច្ចេកទេសផ្តល់ដោយ "អ្នកផ្គត់ផ្គង់"។

ថ្ងៃ...................................ខែ..............ឆ្នាំ................ស័ក ព.ស.២៥៦...

រាជធានីភ្នំពេញ ថ្ងៃទី...............ខែ................ឆ្នាំ២០២៤

**ហត្ថលេខា ត្រា និងឈ្មោះអ្នកដេញថ្លៃ**

# ៦- សេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្ម របស់អ្នកដេញថ្លៃ

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាស
## ស្តីពីក្រមសីលធម៌លទ្ធកម្មរបស់អ្នកដេញថ្លៃ

ខ្ញុំបាទ/នាងខ្ញុំជាប្រធានក្រុមហ៊ុន/សហគ្រាស........................................................................................................ សូមធ្វើការអះអាងក្នុងការរៀបចំសំណើដេញថ្លៃលើការផ្គត់ផ្គង់.............................................................................. ដូចខាងក្រោម៖

១- មិនមាននិយោជិត សហការី ភ្នាក់ងារ ម្ចាស់ភាគហ៊ុន ទីប្រឹក្សា ដៃគូ ឬញាតិសន្តានរបស់ខ្ញុំបាទ/នាងខ្ញុំ មានទំនាក់ទំនងណាមួយដែលអាចចាត់ទុកថាជាទំនាស់ផលប្រយោជន៍ ពាក់ព័ន្ធនឹងការដេញថ្លៃនេះទេ។

២- ប្រសិនបើខ្ញុំបាទ/នាងខ្ញុំដឹងពីលទ្ធភាពដែលអាចកើតមាននូវទំនាស់ផលប្រយោជន៍នេះ ខ្ញុំបាទ/នាងខ្ញុំ នឹងរាយការណ៍ជាបន្ទាន់ជូនស្ថាប័នអនុវត្តលទ្ធកម្ម។

៣- មិនមានការប្រព្រឹត្តអំពើពុករលួយ ក្លែងបន្លំ ឃុបឃិត ឬបង្ខិតបង្ខំ ទាក់ទិននឹងការដាក់សំណើដេញថ្លៃ របស់ក្រុមហ៊ុន/សហគ្រាសរបស់ខ្ញុំបាទ/នាងខ្ញុំ។

ធានាពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

៤- ខ្ញុំបាទ/នាងខ្ញុំយល់ច្បាស់ពីកាតព្វកិច្ចរបស់ខ្លួន ក្នុងការអនុញ្ញាតឲ្យស្ថាប័នមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាល ឬដៃគូអភិវឌ្ឍន៍ធ្វើអធិការកិច្ចលើរាល់លិខិតស្នាមទាំងអស់ទាក់ទងនឹងការដាក់សំណើដេញថ្លៃរបស់ក្រុមហ៊ុន/សហគ្រាស របស់ខ្ញុំបាទ/នាងខ្ញុំនិងកិច្ចសន្យាណាមួយ ដែលជាលទ្ធផលនៃការដាក់ដេញថ្លៃនេះ ដោយមិនគិតថាក្រុមហ៊ុន/សហគ្រាសរបស់ខ្ញុំបាទ/នាងខ្ញុំបាន ឬមិនបានទទួលការសម្រេចប្រគល់កិច្ចសន្យានោះទេ។

៥- គ្មានការទូទាត់ណាមួយ ទាក់ទងនឹងដំណើរការលទ្ធកម្មនេះ ត្រូវបានធ្វើឡើងដោយខ្ញុំបាទ/នាងខ្ញុំ សហការី ភ្នាក់ងារ ម្ចាស់ភាគហ៊ុន ទីប្រឹក្សា ដៃគូរបស់ខ្ញុំបាទ/នាងខ្ញុំ ឬញាតិសន្តានរបស់ពួកគេ ទៅឲ្យភ្នាក់ងារ ទីប្រឹក្សា និយោជិត ឬញាតិសន្តានរបស់ពួកគេ ដែលចូលរួមក្នុងដំណើរការលទ្ធកម្មនេះ ជំនួសមុខឲ្យស្ថាប័នអនុវត្តលទ្ធកម្ម អតិថិជន ឬនិយោជកនោះទេ។

ថ្ងៃ...................................ខែ..............ឆ្នាំ................ស័ក ព.ស.២៥៦...

រាជធានីភ្នំពេញ ថ្ងៃទី..............ខែ................ឆ្នាំ២០២៤

**ហត្ថលេខា ត្រា និងឈ្មោះអ្នកដេញថ្លៃ**

# ៧- ប៉ាន់គំរូ ឬកាតាឡុក

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# ៨- ទម្រង់លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ឧបសម្ព័ន្ធទី៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ/ធនាគារ** .............

# លិខិតធានា

## ប្រាក់កក់ធានាការដេញថ្លៃ

**សូមគោរពជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**

**អគ្គនាយកនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

ដោយហេតុថាក្រុមហ៊ុន/សហគ្រាស ........................................................................................ មានបំណងដាក់សំណើដេញថ្លៃដើម្បីធ្វើការផ្គត់ផ្គង់ខ្សាច់ទន្លេ ដែលត្រូវបើកសំណើដេញថ្លៃនៅថ្ងៃទី.........ខែ........ឆ្នាំ............។

អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ/ធនាគារ សូមធានាចំពោះមុខគណៈកម្មាធិការលទ្ធកម្ម........................... នូវប្រាក់កក់ធានាការដេញថ្លៃចំនួន.................................................................................................................... រៀល ឬដុល្លាអាមេរិក (សរសេរជាអក្សរ.................................................................................................................... រៀល ឬដុល្លាអាមេរិក)។

ក្នុងករណីមានលក្ខខណ្ឌណាមួយកើតមានឡើងក្នុងចំណោមលក្ខខណ្ឌទាំងបីខាងក្រោម៖

១-ប្រសិនបើអ្នកដេញថ្លៃ ដកសំណើដេញថ្លៃរបស់ខ្លួន ក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ

២-ប្រសិនបើអ្នកដេញថ្លៃ បដិសេធការចុះហត្ថលេខាលើកិច្ចសន្យា ក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ

៣-ប្រសិនបើអ្នកដេញថ្លៃ មិនព្រមកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា។

នោះអគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ/ធនាគារ..........នឹងធ្វើការបង្វែរចូលថវិការបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនូវចំនួនប្រាក់កក់ខាងលើ នៅពេលដែលបានទទួលលិខិតស្នើសុំពីគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម... ដែលបញ្ជាក់ថាអ្នកដេញថ្លៃមិនគោរពតាមលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងបីខាងលើ។

លិខិតធានាប្រាក់កក់ធានាការដេញថ្លៃនេះមានសុពលភាព រយៈពេលយ៉ាងតិចសាមសិប(៣០)ថ្ងៃក្រោយសុពលភាពសំណើដេញថ្លៃ។

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ថ្ងៃ....................................ខែ..............ឆ្នាំ....................... ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី.......ខែ...........ឆ្នាំ២០២៤

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ**.........

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# ៩- ទម្រង់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

ឧបសម្ព័ន្ធទី៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានធនាគារជាតិ/ធនាគារ/ធនាគារ** .............

# លិខិតធានា
## ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

**សូមគោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**
**អគ្គនាយកនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

ការិយាល័យលទ្ធកម្មសាធារណៈ

ដោយហេតុថាក្រុមហ៊ុន/សហគ្រាស.................................................................................... បានទទួលលិខិតស្តីពីការចុះកិច្ចសន្យាការផ្គត់ផ្គង់ខ្សាច់ទន្លេ លេខ..................... ចុះថ្ងៃទី............ ខែ........... ឆ្នាំ............. ដែលមានតម្លៃកិច្ចសន្យាចំនួន ........................................ រៀល ឬដុល្លាអាមេរិក (សរសេរជាអក្សរ.................................... រៀល ឬ ដុល្លាអាមេរិក)។

ដោយមានចែងនៅក្នុងលិខិតស្តីពីការចុះកិច្ចសន្យាថា អ្នកផ្គត់ផ្គង់ ត្រូវផ្តល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាចេញដោយអគ្គនាយកដ្ឋានធនាគារជាតិ/ធនាគារ/ធនាគារ... ដែលមានតម្លៃទឹកប្រាក់ស្មើនឹងដប់(១០%)ភាគរយ នៃតម្លៃកិច្ចសន្យាសរុប ដើម្បីជាធានាការអនុវត្តកាតព្វកិច្ចស្របតាមលក្ខខណ្ឌកិច្ចសន្យា។

អគ្គនាយកដ្ឋានធនាគារជាតិ/ធនាគារ/ធនាគារ........................... សូមធានា និងទទួលខុសត្រូវនូវប្រាក់កក់ចំនួន ........................................ រៀល ឬដុល្លាអាមេរិក (សរសេរជាអក្សរ................................................... រៀល ឬដុល្លាអាមេរិក)។

ប្រាក់កក់ខាងលើនេះ នឹងត្រូវបង្វែរចូលថវិការបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅពេលបានទទួលលិខិតស្នើសុំពី "អ្នកទិញ" ដែលបញ្ជាក់ថា "អ្នកផ្គត់ផ្គង់" មិនគោរពតាមលក្ខខណ្ឌនៃកិច្ចសន្យា ហើយក្រុមហ៊ុន/សហគ្រាស ........................ គ្មានសិទ្ធិប្រកែក ឬតវ៉ាឡើយ។

លិខិតធានានេះមានសុពលភាពហូតដល់ ក្រោយថ្ងៃប្រគល់ ទទួលទំនិញគ្រប់ចំនួន ឬក្រោយរយៈពេលធានាគុណភាពទំនិញ។

ថ្ងៃ.....................................ខែ..............ឆ្នាំ....................... ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី.......ខែ...........ឆ្នាំ២០២៤

**អគ្គនាយកដ្ឋានធនាគារជាតិ/ធនាគារ**......

[Disclaimer: The below text is machine translated. For accurate information kindly refer the above text in original language.]

Closing Date: 03-Jul-2024

Kingdom of Cambodia,
Nation, Religion, King
Phnom Penh Post Office
A.C.

Notice
Auction Invitation
Phnom Penh Water Supply Authority would like to inform all enterprises (including
private enterprises) that are properly registered in the Kingdom of Cambodia that Phnom Penh Water
Supply Authority will put a public bid to supply river sand.
Documents for Enterprises to Participate in the Bidding (Including Instructions) Available
at Procurement Unit of Phnom Penh Water Supply Authority at 45, Street 106, Sangkat Srah Chak,
Khan Daun Penh From April 29, 2024 Working hours (800 minutes to 16:30) to Tuesday, February 3, 2024 until 16:00 per copy, price 300,000 Riels. Closing date for receiving and opening the land bidding at 14:00 at the Procurement
Unit of Phnom Penh Water Supply Authority at the end of the above location.
Time
All bids must be accompanied by the mountain in the correct amount in the amount specified in the
bidding documents.
Enterprises affiliated with one or the same source can only bid
Only
one. Enterprises who wish to participate in the bidding, please contact the Procurement Unit to return the bidding documents and ask for information related to this auction, please call 017 811
Delegation of the Royal Government of Cambodia
in charge of Kan Tnaut, Phnom Penh Post
Long Naro
General Department
of the Anti-Corruption Unit
Building 45, Street 106, Sangkat Srah Chak, Khan Daun Penh, Phnom Penh Tel: (855) 3 6   0